ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣៣*៤៤

លេខ : ២៥៧

ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៥ នាមនាមប្រជារាស្ត្រខ្មែរ

សាលដីកា តុលាការកំពូល

លេខ: ២៧ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦

ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឌិត | មុន្ទី | ជាប្រធាន |
| ២-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៣-លោក | យស់ | សួខឿន | ជាចៅក្រម |
| ៤-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រមរបាយការណ៍ |
| ៥-លោក | យូរ | ឧត្តរា | ជាចៅក្រម |

ក្រឡាបញ្ជី

កញ្ញា សេន សុខា

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាដ្ឋប្បវេណីលេខ ៦១"ជ" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤៣៦ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះសោម ខេម (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិកោះពារាំង ឃុំកោះចេក ស្រុកពាមជរ ខេត្តព្រៃវែង ។

ចុងចម្លើយឈ្មោះ ម៉ាក សៀងនី (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៤ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិបឹងលើ ឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្តាល ។

មានមេធាវីលោក ណុប បូផល .

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារគោមួយនឹម .

បានឃើញបណ្តឹងសាទុក្ខលេខ៦០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះម៉ាក សៀងនី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦១"ជ" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៥៧ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី៦-១១-២០០៣ ថាខ្លួនប្តឹងទាមទារយកគោពីឈ្មោះជិន ម៉ាក និងកូនប្រុសឈ្មោះជិន សៀងនី ចំនួនពីរក្បាលមកវិញ ដែលមានទីលំនៅភូមិបឹងលើ ឃុំខ្ពបអាតាវ ស្រុកលើកដែក ខេត្តកណ្តាល ។ ដោយកាលពីថ្ងៃទី១៤-៨-២០០៣ ឈ្មោះជិន ម៉ាក និងកូនប្រុសឈ្មោះសៀងនី បានទៅខ្ចីគោរបស់ខ្លួនទៅដឹកពោតចំនួន៣-៤ថ្ងៃ ដល់ថ្ងៃទី១៩-៨-២០០៣ ខ្លួនបានប្រើប្តីខ្លួនទៅយកគោនោះមកវិញ ដើម្បីភ្ជួររាស់ដីធ្លីរបស់ខ្លួនដែលជារដូវបង្កបង្កើនផល ស្រាប់តែឈ្មោះជិន ម៉ាក និងកូនប្រុសឈ្មោះជិន សៀងនី ពុំព្រមឱ្យគោនោះមកវិញឡើយ ។

តាមពាក្យបណ្តឹងតបរបស់ចុងចំលើយឈ្មោះជិន ម៉ាក ចុះថ្ងៃទី១៨-១១-២០០៣ បានប្តឹងពីឈ្មោះស៊ុត មឿន និងប្រពន្ធឈ្មោះសោម ខេម ដែលបានប្តឹងខ្លួនពីបញ្ហាទាមទារគោ ដែលកើតឡើង ពុំមានការពាក់ព័ន្ធនឹងខ្លួនទេ គឺពាក់ព័ន្ធជាមួយកូនខ្លួនឈ្មោះម៉ាក សៀងនី ដែលបានរៀបការជាមួយកូនស្រីរបស់ស៊ុត មឿន ឈ្មោះមឿន ខេង ហើយបញ្ហារឿងគោនោះ គឺជារបស់កូនរបស់ខ្លួនដែលជាចំណងដៃរបស់ខាងស្រីទៅលើកូនទាំងពីតែប៉ុណ្ណោះ ។

៤ បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះសោម ខេម ចុះថ្ងៃទី០៦-១១-២០០៣ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងតបរបស់ចុងចំលើយឈ្មោះម៉ាក សៀងនី ចុះថ្ងៃទី១៨-១១-២០០៣ ទុកជាត្រឹមត្រូវតាមទំរង់ តែត្រូវបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៣-បង្គាប់ឱ្យឈ្មោះជិន ម៉ាក និងឈ្មោះម៉ាក សៀងនី ប្រគល់គោឈ្មោលមួយនឹមដែលឈ្មោះម៉ាក សៀងនី ជាកូនបានដឹកពីផ្ទះរបស់ដើមចោទឈ្មោះសោម ខេម ឱ្យទៅដើមចោទវិញ និងបង្គាប់ឱ្យឈ្មោះជិន ម៉ាក និងម៉ាក សៀងនី សងជំងឺចិត្ត និងការខាតបង់ក្នុងការបង្កើតផលជាប្រាក់ចំនួន ១០លានរៀល (ដប់លានរៀល) គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ ។ សំណើលើសពីនេះ ត្រូវលើកចោល ។

- ករណីគ្មានប្រាក់សងត្រូវរឹបអូសទ្រព្យសម្បត្តិ លក់ឡាយឡុងដើម្បីទូទាត់សំណង ។
- ករណីរឹងទទឹងត្រូវចាប់ដាក់គុកបង្ខំលើរូបកាយតាមមាត្រា១៣៣នៃច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៤-បង្គាប់ឱ្យឈ្មោះម៉ាក សៀងនី បង់ប្រាក់ប្រដាប់ក្តីសរុបចំនួន៧០០០៛ ក្នុងនោះ

លើពន្ធហ្វ៊ីង និងពន្ធចុះបញ្ជីក្តី ចំនួន១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ និង ប្រាក់ចំណាយក្នុងកិច្ចស៊ើបសួរ ៥០០០៛ ប្រាក់នេះដើមចោទបានបង់រួចហើយ ហើយឱ្យចុងចំលើយសងទៅដើមចោទវិញ កាលបើផុតកំណត់ប្តឹងឧទ្ធរណ៍ ។

៥-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេលពីរខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៤របស់ឈ្មោះ ម៉ាក សៀងនី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៨"ក" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការខេត្តកណ្តាល ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥៣ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២១-៦-២០០៤ របស់ឈ្មោះម៉ាក សៀងនី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី២៨-៥-២០០៤ របស់តុលាការខេត្តកណ្តាល ទុកជាបានការ ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ គឺពន្ធហ្វ៊ីង និងចុះបញ្ជីក្តីចំនួន ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីការកោះ ៥០០០៛ និង ចំណាយលើអាជ្ញាធរតុលាការ ៥០០០៛ សរុបចំនួន ១៣.០០០៛ ។

៤-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចំលើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ១៤១ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤ របស់លោកមេធាវី ណុប បូផល ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៣"ជ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦១"ជ" ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងទាស់ចុះថ្ងៃទី០២-ធ្នូ-២០០៤ របស់ឈ្មោះណុប បូផល មេធាវីការពារក្តីឱ្យឈ្មោះម៉ាក សៀងនី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់គតិច្បាប់

២-តំកល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ៥៣"ជ"ចុះថ្ងៃទី១២-១១-២០០៤ ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខគូក្តី និងមេធាវីការពារឱ្យចុងចំលើយ ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៦០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះម៉ាក សៀងនី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦១"ជ" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះម៉ាក សៀងនី ។

បានឃើញសារណាតបចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះសោម ខេម ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : សាលដីការដ្ឋប្បវេណីលេខ ៦១"ជ" ចុះថ្ងៃទី២៨-១២-២០០៤ របស់សាលាឧទ្ធរណ៍ មានលក្ខណៈត្រឹមត្រូវតាមអង្គច្បាប់ហើយ លើកលែងតែចំណុចជំងឺចិត្ត ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសំរេច ។

បានស្តាប់ចំលើយរបស់ឈ្មោះម៉ាក សៀងនី នាពេលសវនាការថា : តុលាការថ្នាក់ក្រោម កាត់ក្តីឱ្យខ្លួនមិនយុត្តិធម៌ទេ ព្រោះគោមួយនឹមនេះជាចំណងដៃដែលឪពុកក្មេក និងម្តាយក្មេកបាន យកមកចងដៃនៅពេលរៀបអាពាហ៍ពិពាហ៍។លុះពេលរៀបការហើយ ឪពុកក្មេកនិងម្តាយក្មេករបស់ ខ្លួនបានមកពង្រត់យកកូនស្រីរបស់គាត់ទៅវិញ បាត់មិនដឹងជាគាត់យកទៅលាក់នៅឯណាទេ ហើយ បែរជាចោទខ្លួនថា ខ្លួនបានទៅខ្ចីគោរបស់គាត់យកមកជីកពោតទៅវិញ ។ ឥឡូវនេះគោនេះ ចោរ បានលួចបាត់ទៅហើយ ។

បានស្តាប់ចំលើយរបស់អ្នកស្រីសោម ខេម នាពេលសវនាការថា : គោនេះកូនប្រសារ របស់ខ្លួនបានទៅខ្ចីខ្លួនយកទៅជីកពោត លុះក្រោយមកខ្លួនក៏បានទៅយកវិញ ស្រាប់តែកូនប្រសារ របស់ខ្លួនមិនព្រមឱ្យ បែរជានិយាយថា គោនេះគ្រាន់ថា ទុកជាចំណងដៃក្នុងថ្ងៃរៀបការទៅវិញ ។ តែខ្លួនមិនបានឱ្យជាចំណងដៃអ្វីទេ ព្រោះនៅមានកូនតូចៗក្រោយទៀត ។ ខ្លួនសំណូមពរសុំទាម ទារគោរបស់ខ្លួនវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ណុប បូផល ជាមេធាវីការពារឱ្យចុងចំលើយ បាន លើកឡើងថា : រឿងនេះកូនក្តីខ្លួនមានសាក្សីច្រើនណាស់ តែតុលាការថ្នាក់ក្រោមពុំបានយកមក ពិចារណាសោះ ។ ហើយក្នុងរឿងនេះកើតចេញមកពីការមិនចុះដំណោកនឹងគ្នា បានជាមានរឿង ដូចនេះ លុះមានការចុះចេញក៏មានការដេកហូតយកគោនេះមកវិញ ដោយមានចាស់ៗដឹងឮ ។ ដូច នេះតាមរយៈគោនេះ គឺអ្នកស្រីសោម ខេម និងប្តីបានចែកឱ្យកូនជាចំណងដៃក្នុងការរៀបអាពាហ៍ ពិពាហ៍ ហើយក្រោយមកកើតមានទំនាស់ក្នុងការមិនចុះដំណោកមក ក៏កើតជារឿងថា ឱ្យគោទៅ កូនប្រសារខ្ចីដើម្បីទៅជីកពោតទៅវិញ ។ មិនតែប៉ុណ្ណោះអ្នកស្រីសោម ខេម បានព្យាយាមអូស ទាញឪពុកលោកម៉ាក សៀងនី ឱ្យចូលក្នុងរឿងនេះ ដើម្បីទាមទារសំណងក្នុងការទារថ្លៃគោនេះ តាមពិតរឿងនេះជារឿងរបស់កូនទេ ។

ហេតុនេះ ខ្លួនសុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចំលើយរបស់គូភាគី

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

# តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៦០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះម៉ាក សៀងនី ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងច្បាស់លាស់បញ្ជាក់ថា ចុងចំលើយពិតជាខ្ចីគោមួយនឹមរបស់ដើមចោទយកទៅជីកសណ្តែកប្រាកដមែន ដូចនេះចុងចំលើយមានភាតព្វកិច្ចសងវត្ថុខ្ចីឱ្យទៅដើមចោទវិញ តាមមាត្រា២៤,២៩,៩៨ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចឱ្យចុងចំលើយសងប្រាក់ជំងឺចិត្តចំនួន១០លានរៀលនោះ ជាបន្ទុកធ្ងន់ធ្ងរពេក ម្យ៉ាងទៀត សាលាឧទ្ធរណ៍មិនបានលើកសំអាងហេតុអំពីការខូចខាតនេះឡើយ ដែលចំណុចនេះបំពានលើមាត្រា ២០៩ ចំណុច ៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦១ "ជ" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ ឯគតិច្បាប់ត្រូវខ្លះ ខុសខ្លះ ។

## ហេតុដូចនេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី និងចោទជាចុងចំលើយ

១-ទទួលបណ្តឹងសាទុក្ខលេខ ៦០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះម៉ាក សៀងនី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ឯគតិច្បាប់បដិសេធខ្លះ តំកល់ខ្លះ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ៦១"ជ" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែផ្នែកជំងឺចិត្តនៅក្នុងចំណុចទី៣ នៃសាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការខេត្តកណ្តាល ត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៥៧ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់ចំណុចជំងឺចិត្ត ។

៤-រឹបអូសប្រាក់ប្រដាប់ភ្លើដែលអ្នកស្រីសោម ខេម បានបង់ជូសទុកនៅតុលាការកំពូលចំនួន ១៩០០០៛ គឺ :

-ពន្ធចុះបញ្ជីភ្លើ និងពន្ធហ្គីងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

តំរូវឱ្យលោកម៉ាក សៀងនី សងប្រាក់ចំនួន ៩៥០០៛ ទៅឱ្យអ្នកស្រីសោម ខេម វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៧ខែមករាឆ្នាំ២០០៦ ។